ក្រុមប្រឹក្សារដ្ឋស្តីពីអសមត្ថភាពខាងការអភិវឌ្ឍន៍ (State Council on Developmental Disability, SCDD) មានបេសកកម្មមួយដើម្បីបញ្ជាក់ថាពលរដ្ឋដែលមានពិការភាពខាងប្រាជ្ញា និងការអភិវឌ្ឍន៍ និងគ្រួសាររបស់ខ្លួនទទួលបានព័ត៌មាន សេវានិងកិច្ចគាំទ្រក្នុងសហគមន៍អំពីជម្រើសរបស់ពួកគេ ទូទាំងរដ្ឋ California ។

ក្រុមប្រឹក្សារដ្ឋស្តីពីអសមត្ថភាពខាងការអភិវឌ្ឍន៍មានអំណរគុណដែលមានពលរដ្ឋជាច្រើនរួបផ្ញើយតបនឹងការស្នង់មតិផែនការរដ្ឋរបស់គេ ។ មានចំនួនផ្ញើយតបសរុប 6,329 ត្រូវបានទទួលតាមអ៊ីមែលនិងតាមរយៈការបំពាក់បំប៉និងព្រឹត្តិការណ៍សហគមន៍ (ការស្នង់មតិត្រូវបានផ្តល់ក្នុង 17 ភាសាខុសៗគ្នា បន្ថែមទៅលើភាសាអង់គ្លេស) ។ រាល់ការផ្ញើយតបទាំងអស់ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ (ខ្វាល់ទ្រីកស៍) របស់ក្រុមប្រឹក្សារដ្ឋនិងវិភាគ ដើម្បីកំណត់បញ្ហាដែលសំខាន់បំផុតសម្រាប់មនុស្សពិការខាងបញ្ញា / ការអភិវឌ្ឍន៍ក្រុមគ្រួសាររបស់ពួកគេនិងអ្នកដទៃទៀតនៅរដ្ឋ California ។ ការផ្ញើយតបនៃការស្នង់មតិបានបង្ហាញថាពលរដ្ឋពិការភាពមានកង្វល់បំផុតអំពីការងារ លំនៅដ្ឋាន ការអប់រំ និងសុខភាព/សុវត្ថិភាព ។ ពលរដ្ឋជាមួយពិការភាពខាងបញ្ញា/ការអភិវឌ្ឍន៍បាននិយាយថា ការងារគឺសំខាន់បំផុតចំពោះពួកគេ ។ បុគ្គលិកបានទទួលការស្នង់មតិ 1,530 ក្នុងភាសាអេសប្យាញ/ឡាតាំង រួមទាំងការស្នង់មតិ 496 ក្នុងតែភាសាស្ពែនីសប៉ុណ្ណោះ ។ សម្រាប់ពលរដ្ឋនិយាយភាសាស្ពែនីស ការអប់រំគឺជាកង្វល់សំខាន់បំផុតរបស់ពួកគេ។

ផ្អែកលើតម្រូវការសហព័ន្ធសម្រាប់ការងាររបស់ក្រុមប្រឹក្សា គោលដៅដែលបានស្នើត្រូវបានបែងចែកជាបី (3) ផ្នែក៖ ការតស៊ូមតិដោយខ្លួនឯង ការផ្លាស់ប្តូរប្រព័ន្ធ / ការតស៊ូមតិ និងការកសាងសមត្ថភាព / ការតស៊ូមតិ ។ សម្រាប់គោលបំណងរបស់ផែនការរដ្ឋ បុគ្គលិកបានវិភាគប្រភេទការងារដែលប្រជាជននៅរដ្ឋ California បានស្នើសុំឱ្យក្រុមប្រឹក្សាធ្វើ។ ការងារនេះរួមមានការបណ្តុះបណ្តាល ជំនួយបច្ចេកទេសព្រឹត្តិការណ៍និងគម្រោងពិសេស និងការផ្តល់ព័ត៌មាននិងធនធាន ។ ចំពោះគោលនយោបាយ គម្រោងពិសេស និងប្រព័ន្ធផ្លាស់ប្តូរការងារ សមាជិកគណៈកម្មាធិការសំរេចចិត្តផ្តោតលើវិស័យការងារ ការអប់រំ លំនៅដ្ឋាន និងសុខភាព / សុវត្ថិភាព ។ សម្រាប់ការបណ្តុះបណ្តាលនិងជំនួយបច្ចេកទេស បុគ្គលិកក្រុមប្រឹក្សានឹងផ្តល់ព័ត៌មាន ការបណ្តុះបណ្តាល និងធនធានលើគ្រប់វិស័យដែលមានសារៈសំខាន់សម្រាប់ជនពិការនិងគ្រួសាររបស់ពួកគេ ។

ចំនួននៃសកម្មភាពដែលក្រុមប្រឹក្សាកំពុងតែគ្រោងធ្វើនិងចំនួននៃពលរដ្ឋដែលវាគ្រោងនឹងទំនាក់ទំនងទាំងអស់គឺសំអាងទៅលើ ៖ 1) ការវិភាគការងារដែលបានបញ្ចប់ក្នុងរយៈពេលប្រាំ (5) ឆ្នាំកន្លងមករួមទាំងចំនួនសកម្មភាព ដែលបានផ្តល់និងចំនួនប្រជាជនបានទៅដល់; 2) សមត្ថភាពបុគ្គលិកក្រុមប្រឹក្សានិងធនធានដែលមានជូន និងទី 3) ការអភិវឌ្ឍនិងការអនុវត្តផែនការការងារប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា។ ចំនួនដែលបានផ្តល់ជូននៅក្នុងសេចក្តីព្រាងគោលបំណងនៃផែនការរដ្ឋនីមួយៗ នឹងត្រូវបានផ្សព្វផ្សាយក្នុងរយៈពេលប្រាំ (5) ឆ្នាំនៃឆ្នាំបន្តបន្ទាប់ (2022-26) ។

ផ្អែកទៅលើការធ្វើយតបការស្នង់មតិ (ជាមួយនឹងការអធិប្បាយរាប់ពាន់) និងការស្រាវជ្រាវ
ដែលបានផ្តល់ដោយបុគ្គលិកក្រុមប្រឹក្សា គណៈកម្មាធិការផែនការរដ្ឋរបស់ក្រុមប្រឹក្សាបាន
បង្កើតផែនការរដ្ឋ ដែលបានស្នើឡើងរបស់ខ្លួន ។ ក្រុមប្រឹក្សាកំពុងតែស្នើសុំការត្រួតពិនិត្យ
សាធារណៈ និងការអធិប្បាយទៅលើផែនការរដ្ឋ California ឆ្នាំ 2022-26 បានស្នើឡើង
របស់ខ្លួន ។ អំឡុងពេលការអធិប្បាយសាធារណៈនេះនឹងបើកចំហរទទួលសម្រាប់ 45 ថ្ងៃ ។

ផែនការរដ្ឋឆ្នាំ 2022-26 បានស្នើឡើង

គោលដៅទី 1: ការតស៊ូមតិដោយខ្លួនឯង

**ក្រុមប្រឹក្សានឹងផ្តល់អំណាចដល់ពលរដ្ឋជាមួយនឹងការអសមត្ថិភាពខាងបញ្ញា/
ការអភិវឌ្ឍន៍ ឲ្យមានជំហរ រឹងមាំ ចំពោះការតស៊ូមតិខ្លួនឯង អ្នកបំពាក់បំប៉ន់មាន
អាយុប្រហាក់ប្រហែលគ្នា និងថ្នាក់ដឹកនាំសហគមន៍ ។**

គោលបំណងទី 1

ក្រុមប្រឹក្សានឹងផ្តល់ព័ត៌មាន ធនធាន និងការបំពាក់បំប៉ន់ដើម្បីពង្រឹង
ការតស៊ូមតិខ្លួនឯង ចំនួន 1,250 ក្នុង៖

1) កំណត់និងស្នើសុំកិច្ចគាំទ្រនិងសេវាដែលពួកគេត្រូវការ;
2) ក្លាយទៅជា និងបម្រើក្នុងនាមជាអ្នកបំពាក់បំប៉ន់មិត្តភក្តិ; និង
3) អភិវឌ្ឍន៍ការស្គាត់ជំនាញនិងឱកាសដើម្បីចូលរួមក្នុងនាមជា
សកម្មជនដ៏រឹងប៉ឹង ចំពោះបញ្ហាដែលមានសារៈសំខាន់សម្រាប់ពួកគេនិងក្រុម
គ្រួសាររបស់ពួកគេ។

គោលបំណងទី 2

ក្រុមប្រឹក្សានឹងគាំទ្រដល់អ្នកតស៊ូមតិដោយខ្លួនឯង នៅក្នុងបណ្តាញមិត្តភក្តិដោយផ្តល់
ការសម្រប សម្រួល ការគាំទ្រជាក់ស្តែងនិងឱកាសតស៊ូមតិ / ដៃគូដឹកនាំតាមរយៈអង្គភាព
តស៊ូមតិដោយខ្លួនឯងក្នុងតំបន់យ៉ាងហោចណាស់ 1 រដ្ឋនិង 12 ដែលទំនាក់ទំនងទៅ
ការតស៊ូមតិដោយខ្លួនឯង ចំនួន 6,000 នាក់ ។

គោលដៅទី 2៖ ការផ្លាស់ប្តូរប្រព័ន្ធ/ការតស៊ូមតិ

ក្រុមប្រឹក្សានឹងដឹកនាំក្នុងភាពជាដៃគូជាមួយក្រុមគ្រួសារ / អ្នកតស៊ូមតិដោយខ្លួនឯងនិងអ្នកដទៃទៀត ដើម្បីការពារនិងលើកស្ទួយសិទ្ធិស៊ីវិលនិងកែលម្អប្រព័ន្ធសហគមន៍ ដើម្បីឱ្យមានការចូលរួមពេញលេញនិងគាំទ្រដល់ជនមានពិការភាពខាងបញ្ញា / ការអភិវឌ្ឍនិងគ្រួសាររបស់ពួកគេ ។

គោលបំណងទី 1

ក្រុមប្រឹក្សានឹងអភិវឌ្ឍន៍ ធ្វើឱ្យប្រសើរឡើងនិង / ឬផ្លាស់ប្តូរការអនុវត្ត 30 គោលនយោបាយ 15 និងបទប្បញ្ញត្តិចំនួន 10 (ឬការណែនាំ) និង / ឬចូលរួមនៅ ក្នុងប្រព័ន្ធនៃមជ្ឈមណ្ឌលតំបន់សេវាកម្មសហគមន៍ និងអង្គភាពរដ្ឋាភិបាល ។ ការងារនេះនឹងរួមមានវិស័យការងារ ការអប់រំ លំនៅដ្ឋាន និងសុខភាព / សុវត្ថិភាព តាមរបៀបដែលនឹងផ្តល់ផលប្រយោជន៍ដល់ជនពិការខាងបញ្ញានិងការអភិវឌ្ឍ និងការពារសិទ្ធិស៊ីវិល លើកកម្ពស់ការរាប់បញ្ចូលពេញលេញ និង / ឬផ្តល់ការគាំទ្រនិងសេវាកម្មបន្ថែម ធ្វើឱ្យជីវិតរបស់ពួកគេមានភាពប្រសើរឡើង។ តាមរបៀបជាក់ស្តែង។

គោលបំណងទី 2

ក្រុមប្រឹក្សានឹងចូលរួមក្នុងគំរោងចំនួន 20 / តំបន់និងគំរោងច្នៃប្រឌិតថ្មីនិង / ព្រឹត្តិការណ៍ច្នៃប្រឌិតថ្មីក្នុងតំបន់និងចំនួន 5 នៅក្នុងរដ្ឋចំនួន 20 នៅក្នុងវិស័យការងារ ការអប់ រំលំនៅដ្ឋាន និងសុខភាព / សុវត្ថិភាពដល់៖

1) ផ្តល់អំណាចដល់ពលរដ្ឋ 5,000 នាក់ (ក្រុមគ្រួសារ / អ្នកតស៊ូមតិដោយខ្លួនឯងនិងអ្នកផ្សេងទៀត) នៅក្នុងប្រព័ន្ធផ្លាស់ប្តូរការខិតខំប្រឹងប្រែងនិងផ្តល់ឱ្យពួកគេនូវព័ត៌មានជំនាញនិង / ឬការគាំទ្រដើម្បីបង្កើនសមត្ថភាពរបស់ពួកគេ ដើម្បីក្លាយជាអ្នកតស៊ូមតិប្រកបដោយប្រសិទ្ធភាព; និង / ឬ

2) បង្កើនចំនួនសេវាដើម្បីធ្វើឱ្យកិច្ចគាំទ្របានប្រសើរឡើង សម្រាប់ពលរដ្ឋជាមួយនឹងពិការភាពខាងបញ្ញា/ការអភិវឌ្ឍន៍ និងក្រុមគ្រួសាររបស់ពួកគេ ។

គោលបំណងទី 3

ក្រុមប្រឹក្សាសហការជាមួយដៃគូសហព័ន្ធចំនួនបួន (4) របស់រដ្ឋ California (ទីភ្នាក់ងារការពារនិងតស៊ូមតិនិងមជ្ឈមណ្ឌលសាកលវិទ្យាល័យ សម្រាប់ឧត្តមភាពក្នុងការអភិវឌ្ឍពិការភាព) នឹងវាយតម្លៃលើប្រព័ន្ធសេវាកម្មទូទៅដែលជះឥទ្ធិពលដល់ជនពិការបញ្ញា / ការអភិវឌ្ឍដោយជ្រើសរើស ផ្នែកនៃការបញ្ជាក់នៅក្នុងផែនការរដ្ឋ រួចជាការអប់រំ ការងារ លំនៅដ្ឋាន សុខភាព ឬសុវត្ថិភាព និងរបាយការណ៍អំពីរបៀបដែលប្រព័ន្ធសេវាទូទៅបច្ចុប្បន្នកំពុងបម្រើដល់ប្រជាជន ដែលមានពិការភាពដខាងបញ្ញា / ការអភិវឌ្ឍ (រាប់បញ្ចូលទាំងមនុស្សដែលបានបម្រើនិងមិនបម្រើដោយ ប្រព័ន្ធមជ្ឈមណ្ឌលប្រចាំតំបន់) គម្លាតក្នុងការផ្តល់សេវាកម្មនៅក្នុងប្រព័ន្ធអនុសាសន៍ស្តីពីវិធីកែលម្អប្រព័ន្ធ ដើម្បីធ្លើយតបទៅនឹងគោលដៅនៃច្បាប់ DD Act និងបន្តគោលនយោបាយនិងការផ្លាស់ប្តូរការអនុវត្ត។ ការចូលសហការណ៍នឹងផ្តល់ជាលទ្ធផលក្នុងរបាយការណ៍ 2 អនុសាសន៍ 6 សម្រាប់គោលនយោបាយឬ ការផ្លាស់ប្តូរការអនុវត្ត និងការផ្លាស់ប្តូរឬពីរចំពោះគោលនយោបាយ ឬការអនុវត្ត ។

គោលដៅទី 3: ការបង្កើតសមត្ថិភាព/ការតស៊ូមតិ

ក្រុមប្រឹក្សានឹងចូលជាដៃគូជាមួយ និងផ្តល់អំណាចកាន់តែច្រើនដល់ពលរដ្ឋពិការ ខាងបញ្ញា/ការអភិវឌ្ឍន៍ និងគ្រួសាររបស់ពួកគេ ដើម្បីជួយពួកគេដឹងអំពីសិទ្ធិរបស់ពួកគេ និងអាចទទួលបានកិច្ចគាំទ្រ និងសេវាផ្សេងៗ។

គោលបំណងទី 1

ក្រុមប្រឹក្សានឹងផ្តល់ការបណ្តុះបណ្តាល (ដឹកនាំដោយបុគ្គលិកដឹកនាំនិង / ឬសហការ) ដល់ប្រជាជនចំនួន 60,000 នាក់ (ក្រុមគ្រួសារ / អ្នកតស៊ូមតិខ្លួនឯង / អ្នកផ្សេងទៀត) នៅ ទូទាំងរដ្ឋ - ស្មើរតែតាមអ៊ីនធរណេតនិង / ឬដោយផ្ទាល់ - និងផ្តល់ជំនួយបច្ចេកទេស (TA) ក្នុងនិកតស៊ូមតិឈានដល់ 50,000 នាក់ដោយមានជំនួយនិងធនធាន ដើម្បីកំណត់និងទទួលបានការគាំទ្រនិងសេវាកម្ម ដែលនឹងជួយមនុស្សពិការខាងបញ្ញា / ការអភិវឌ្ឍ អោយរស់នៅប្រកបដោយសុវត្ថិភាពនិងសុខភាពល្អ។

គោលបំណងទី 2

ក្រុមប្រឹក្សានឹង ចូលរួមក្នុងគម្រោង និងព្រឹត្តិការណ៍100 ក្នុងវិស័យនៃការងារ ការអប់រំ លំនៅដ្ឋាន សុខភាព/សុវត្ថិភាព និងបញ្ហាកកើតឡើងដែលជាប់ទាក់ទងជាមួយពលរដ្ឋ 25,000 នាក់ (ក្រុមគ្រួសារ/អ្នកតស៊ូមតិ/អ្នកដទៃទៀត) ជាមួយនឹងព័ត៌មាននិងធនធានដើម្បីពង្រីកតំរិះចេះដឹងរបស់ពួកគេ និងបង្កើនសមត្ថភាពរបស់ពួកគេ ដើម្បីទទួលបានកិច្ចគាំទ្រនិងសេវាដែលសំខាន់ចាំបាច់សម្រាប់ពួកគេ។

គោលបំណងទី 3

ដើម្បីកាត់បន្ថយភាពខុសគ្នាក្នុងការទទួលបានការអប់រំសាធារណៈ:សមរម្យ និងឥតគិតថ្លៃ ក្រុម ប្រឹក្សានឹងធ្វើការជាមួយអ្នកតស៊ូមតិគ្រួសារ / អ្នកនិយាយដោយខ្លួនឯងជាភាសាស្ពេនិស ចំនួន 5,000 នាក់ នៅទូទាំងរដ្ឋ ដើម្បីតស៊ូមតិនិងបង្កើនចំនួននិងប្រភេទ / គុណភាពនៃសេវាកម្មអប់រំពិសេស ដែលពួកគេទទួលបានតាមរយៈ ទីភ្នាក់ងារអប់រំ ក្នុងស្រុករបស់ពួកគេផ្ទាល់។

[សូមចែករំលែកការអធិប្បាយរបស់អ្នក]